# ពិធីការបើកឡើងវិញសម្រាប់រោងភាពយន្តបើកចូល

**កាលបរិច្ឆេទមានប្រសិទ្ធភាព៖ ម៉ោង 12:01 រំលងអាធ្រាត ថ្ងៃព្រហស្បតិ៍ ទី6 ខែឧសភា ឆ្នាំ 2021**

**បច្ចុប្បន្នភាពថ្មីៗ៖** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**5/5/21៖**

- ឡានដឹកទំនិញអាហារត្រូវបានអនុញ្ញាតឲ្យបើកចូលទៅតាមរោងភាពយន្ត និងព្រឹត្តិការណ៍ផ្សេងៗ។

ផុតកំណត់ - មិនមានប្រសិទ្ធភាព

ពិធីការនេះអនុវត្តទាំងលើអាជីវកម្មរោងភាពយន្តបើកចូលដែលមានស្រាប់ និងបើកថ្មី។ ប្រតិបត្តិការភាពយន្តបើកចូលទាំងអស់ ត្រូវតែមានហេដ្ឋារចនាសម្ព័ន្ធ បុគ្គលិក និងការបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីឆ្លើយតបតាមសេចក្តីបង្គាប់នៃការរក្សាគំលាតរាងកាយ របាំងមុខ និងការធ្វើអនាម័យទាំងអស់។ ទីកន្លែងមានស្រាប់ដែលមានកម្លាំងពលកម្ម បន្ទប់ទឹក និងទីកន្លែងលក់ចំណីអាហារដែលបានអនុញ្ញាតស្រាប់ មានភាពងាយស្រួលជាងក្នុងការឆ្លើយតបតាមសេចក្តីបង្គាប់សុវត្ថិភាព។ សេចក្តីបង្គាប់ជាក់លាក់ចំពោះប្រតិបត្តិការបើកចូលថ្មីដែលកំពុងត្រូវបានរៀបចំនៅក្នុងចំណតយានយន្ត និងទីធ្លាផ្សេងទៀត ដែលមិនមែនជាអាជីវកម្មភាពយន្តបើកចូលដែលបានបង្កើតឡើងពីមុន ត្រូវបានរៀបរាប់នៅខាងចុងពិធីការនេះ។

ប្រតិបត្តិការរោងភាពយន្តបើកចូល ត្រូវតែស្ថិតក្រោមការគ្រប់គ្រងរបស់និយោជកតែមួយ ដែលទទួលបន្ទុកទីកន្លែងនោះ ដែលនឹងទទួលខុសត្រូវចំពោះការបណ្តុះបណ្តាលដែលកំពុងដំណើរការ និងការត្រួតពិនិត្យបុគ្គលិកទាំងអស់ ការផ្តល់បរិក្ខារ និងសម្ភារៈដែលចាំបាច់ទាំងអស់ ការត្រួតពិនិត្យ ការគោរពតាមវិធានការណ៍សុវត្ថិភាពទាំងអស់ក្នុងអំឡុងពេលចាក់បញ្ចាំងណាមួយ និងការទទួលការអនុញ្ញាតពីមន្ត្រីកំពត់ទីតាំង និងមន្ត្រីក្រុង បើសិនជាចាំបាច់។

រោងភាពយន្តបើកចូល អាចចាក់បញ្ចាំងខ្លឹមសារដែលបានត្រៀមផ្ទាល់ ដែលត្រូវបានថតនៅកន្លែងផ្សេង ដរាបណាការថតគោរពតាមសេចក្តីបង្គាប់ដែលបានរៀបរាប់យ៉ាងលម្អិតនៅក្នុងឧបសម្ព័ន្ធ J។

សេវាកម្មម្ហូបអាហារទាំងឡាយ ត្រូវតែមកពីភោជនីយដ្ឋាននៅនឹងកន្លែង ឬតូបលក់អាហារសម្រន់ដែលបានអនុញ្ញាត ឡានដឹកទំនិញអាហារ ឬម្ហូបអាហារដែលបានវេចខ្ចប់ជាមុនពីទីផ្សារដែលបានអនុញ្ញាតដោយផ្នែកសុខភាពបរិស្ថាន។ ម្ហូបអាហារអាចទិញ និងមកយកនៅនឹងកន្លែង ឬបញ្ជាទិញតាមរយៈសេវាកម្មដឹកជញ្ជូនភាគីទីបី និងដឹកជញ្ជូនទៅកាន់យានយន្តរបស់អតិថិជន។ អតិថិជនត្រូវតែបរិភោគម្ហូបអាហារ និងភេសជ្ជៈនៅក្នុងយានយន្តរបស់ខ្លួន។ ទីកន្លែងលក់ម្ហូបអាហារទាំងនេះ ត្រូវតែគោរពតាមពិធីការបើកឡើងវិញ សម្រាប់ភោជនីយដ្ឋាន និង/ឬសេវាកម្មម្ហូបអាហារជាធរមានទាំងអស់។ អ្នកចូលរួមអាចយកម្ហូបអាហាររបស់ខ្លួនមកជាមួយបាន។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្ត្រតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញកាសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឲ្យអាជីវកម្មលក់រាយបើកទ្វារឡើងវិញដោយសុវត្ថិភាព។ សេចក្តីបង្គាប់ខាងក្រោមគឺជាក់លាក់សម្រាប់រោងភាពយន្តបើកចូល ដែលត្រូវបានអនុញ្ញាតឲ្យបើកដំណើរការឡើងវិញក្រោមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាល។ បន្ថែមលើល័ក្ខខ័ណ្ឌដែលបានដាក់ចុះទៅលើអាជីវកម្មទាំងនេះ ដោយមន្ត្រីសុខាភិបាលសាធារណៈរដ្ឋ អាជីវកម្មភាពយន្តបើកចូលក៏ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងបញ្ជីត្រួតពិនិត្យសម្រាប់រោងភាពយន្តបើកចូល (Checklist for Drive-in Movie Theaters) និងពិធីការបើកឡើងវិញសម្រាប់ភោជនីយដ្ឋានផងដែរ។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្នភាពផ្សេងៗ ទៅលើឯកសារនេះ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក

(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ

(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណៈជន

(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំងប្រាំនេះត្រូវតែបានដោះស្រាយ នៅពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**អាជីវកម្មទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត ដោយសារភាពមិនសមស្របសម្រាប់អាជីវកម្ម។**

**ឈ្មោះអាជីវកម្ម៖** ______________________________

**អាសយដ្ឋានទីកន្លែង៖** ______________________________

**កាលបរិច្ឆេទចុះផ្សាយ៖** ______________________________

**កំណត់សម្គាល់៖ នៅក្នុងពិធីការនេះ ពាក្យ "រថយន្ត" ត្រូវបានប្រើដើម្បីចង្អុលបង្ហាញរថយន្ត រថយន្តដឹកទំនិញ រថយន្តដឹកទំនិញតូចៗ រថយន្តបោះតង់ ឬយានយន្តផ្សេងៗទៀតដែលត្រូវបានប្រើជាប្រចាំសម្រាប់ការដឹកជញ្ជូនឯកជន។ ទីកន្លែងអាចដាក់កម្រិតលើប្រភេទ ឬទំហំនៃយានយន្តដែលត្រូវបានអនុញ្ញាតតាមការចាំបាច់។**

## A. គោលការណ៍កន្លែងធ្វើការ និងការអនុវត្តដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ ឬអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។
- ❑ បុគ្គលិកទាំងអស់ (រាប់បញ្ចូលទាំងបុគ្គលិកទទួលប្រាក់ឈ្នួល អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត ត្រូវបានសំដៅជារួមថា "បុគ្គលិក") ត្រូវបានប្រាប់មិនឲ្យមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយមនុស្សដែលមានជំងឺ COVID-19។ បុគ្គលិកយល់និងអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងការនៅដាច់ពីគេ បើសិនជាអាចអនុវត្តបាន។ គោលការណ៍សុំច្បាប់ឈប់សម្រាកនៅកន្លែងធ្វើការត្រូវបានពិនិត្យឡើងវិញ និងបានកែប្រែដើម្បីធានាថាបុគ្គលិកមិនត្រូវបានពិន័យនៅពេលពួកគេស្ថិតនៅផ្ទះដោយសារជំងឺ។
- ❑ ព័ត៌មានអំពីអត្ថប្រយោជន៍នៃការសុំច្បាប់ឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ មើលព័ត៌មានបន្ថែមស្តីពី កម្មវិធី រដ្ឋាភិបាលដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ឈប់សម្រាកដោយជំងឺCOVID-19បន្ថែមនៅឆ្នាំ 2021។
- ❑ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញ ទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិកធ្វើការងារពីផ្ទះ។
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យមានការដាក់ខ្លួនឲ្យនៅដាច់ពីគេ ភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬទេ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ មើលការណែនាំសុខភាពសាធារណៈនៅលើ ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ ការត្រួតពិនិត្យច្រកចូលត្រូវបានធ្វើឡើងមុនពេលបុគ្គលិក ក្រុមការងារ តន្ត្រីករ និងអ្នកសំដែងរួមទាំងអ្នកដទៃទៀត អាចចូលទៅក្នុងទីតាំងអាជីវកម្មទាំងខាងក្នុង ឬខាងក្រៅអគារ។ ការពិនិត្យនេះ

ត្រូវតែឆែកមើលលើស្ថានភាពពាក់ព័ន្ធនឹងគ្រុនក្តៅឬគ្រុនរងា ការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងលែងដឹងរសជាតិឬក្លិនថ្មី និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬការធ្វើចត្តាឡីស័ក (ដាក់ឲ្យដាច់ពីគេ)នាពេលថ្មីៗនេះ។ (សូមមើល ការណែនាំរបស់ខោនធីអំពីការត្រួតពិនិត្យច្រកចូល។) ការត្រួតពិនិត្យទាំងនេះអាចធ្វើទៅបានដោយផ្ទាល់ ឬតាមរយៈវិធីសាស្ត្រជំនួសដូចជាការត្រួតពិនិត្យតាមអនឡាញដោយប្រើប្រព័ន្ធប្រតិបត្តិ ផ្លាកសញ្ញា ឬតាមរយៈដែលមានបិទនៅច្រកចូលនៃបរិវេណអាជីវកម្មដែលបញ្ជាក់ថាភ្ញៀវណាដែលមានរោគសញ្ញាទាំងនេះមិនត្រូវចូលក្នុងបរិវេណឡើយ។

- ប្រសិនបើបុគ្គលនោះមិនមានរោគសញ្ញា និងមិនកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬការធ្វើចត្តាឡីស័ក (ដាក់ឲ្យដាច់ពីគេ)នាពេលថ្មីៗនេះ និងគ្មានទំនាក់ទំនងជាមួយករណីនៃជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយនេះទេ ពួកគេអាចត្រូវបានបញ្ជាក់ថាមិនមានបញ្ហាក្នុងការចូល និងចូលរួមសម្រាប់ថ្ងៃនោះ។
- ប្រសិនបើបុគ្គលនោះមិនបានចាក់វ៉ាក់សាំង[1]ប្រឆាំងជំងឺ COVID-19 ពេញលេញទេ ហើយបានប៉ះពាល់នឹងករណីជំងឺCOVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬថ្មីៗនេះកំពុងស្ថិតនៅក្រោមការដាក់ឲ្យធ្វើចត្តាឡីស័ក(នៅដាច់ដោយឡែក) ត្រូវតែបញ្ជូនពួកគេទៅផ្ទះភ្លាមៗដើម្បីដាក់ឲ្យនៅដាច់ពីគេនៅក្នុងផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការធ្វើចត្តាឡីស័ក (នៅដាច់ដោយឡែក)ដល់ពួកគេ ដែលមាននៅលើគេហទំព័រ ph.lacounty.gov/covidquarantine។ បុគ្គលដែលបានចាក់វ៉ាក់សាំងពេញលេញ ឬដែលបានជាសះស្បើយពីជំងឺ COVID-19 ដោយមានការបញ្ជាក់ពីមន្ទីរពិសោធន៍ក្នុងរយៈពេល 90 ថ្ងៃចុងក្រោយ មិនចាំបាច់ធ្វើចត្តាឡីស័កទេបន្ទាប់ពីប៉ះពាល់នឹងករណីជំងឺ COVID-19 ក្នុងរយៈពេល10 ថ្ងៃចុងក្រោយ ប្រសិនបើពួកគេនៅតែមិនមានរោគសញ្ញាអ្វីនោះ។ បុគ្គលដែលមានការវិវត្តទៅជារោគសញ្ញានៃជំងឺ COVID-19 ត្រូវតែដាក់ខ្លួនឲ្យនៅដាច់ដោយឡែកពីគេ។
- ប្រសិនបើបុគ្គលនោះបង្ហាញរោគសញ្ញាដូចដែលបានកំណត់សម្គាល់ដូចខាងលើ ឬកំពុងស្ថិតនៅក្រោមការបញ្ជាដាក់ឲ្យនៅដាច់ដោយឡែកពីគេ ហើយត្រូវតែបញ្ជូនពួកគេទៅផ្ទះវិញភ្លាមៗ ដើម្បីដាក់ឲ្យនៅដាច់ដោយឡែកពីគេនៅផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការនៅដាច់ដោយឡែកដល់ពួកគេ ដែលមាននៅលើគេហទំព័រ ph.lacounty.gov/covidisolation។

❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកគួររាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821 ឬតាមអនឡាញនៅ www.redcap.link/covidreport។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាចង្កោម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍ពីការគ្រប់គ្រងការឆ្លងជំងឺ ជំនួយបច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈនឹង ត្រូវបានចាត់តាំង ដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាចង្កោម ដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។

❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃ ទទួលបានម៉ាស់សមស្របដែលគ្របច្រមុះនិងមាត់ដោយឥតគិតថ្លៃ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័ររបស់ LAC DPHអំពីម៉ាស់ការពារជំងឺ COVID-19 តាមរយៈ http://publichealth.lacounty.gov/acd/ncorona2019/masks។ បុគ្គលិកត្រូវតែពាក់ម៉ាស់គ្រប់ពេលវេលា ក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ ត្រូវពាក់សន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាល័ក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹតតឹងនៅខាងក្រោមចង្កា។

---

[1]បុគ្គលដែលត្រូវបានគេចាត់ទុកថាជាការចាក់វ៉ាក់សាំងប្រឆាំងមេរោគCOVID-19គ្រប់ចំនួននឹកគិតចាប់ពី ច្រើនជាង ≥2សប្តាហ៍ បន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរនៃប្រភេទវ៉ាក់សាំង (រួមមានPfizer -BioNTech ឬ Moderna) ឬច្រើនជាង ≥2សប្តាហ៍ បន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃប្រភេទដូសតែមួយដងរួចរាល់ហើយ (រួមមាន Johnson and Johnson [J&J]/Janssen។

ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវគឺមិនត្រូវប្រើឡើយ។

- ❑ បុគ្គលិកទាំងអស់ត្រូវតែពាក់ម៉ាស់គ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជនដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ករណីលើកលែងដែលមានសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូចដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់របស់បុគ្គលិក ពេលនេះត្រូវបានលុបចោល។
- ❑ ដើម្បីធ្វើឲ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានរារាំងមិនឲ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគំលាតរវាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក គួរធ្វើដូច្នោះនៅខាងក្រៅអគារនិងឆ្ងាយពីអ្នកដទៃ បើសិនជាអាចធ្វើបាន។ ការបរិភោគ ឬការផឹក នៅបន្ទប់តូច ឬស្ថានីយការងារគឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាកបើសិនជាការបរិភោគនៅបន្ទប់តូច ឬស្ថានីយការងារផ្ដល់ជូនគំលាតកាន់តែធំ និងរបាំងរវាងបុគ្គលិក។
- ❑ ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគំលាតរវាងបុគ្គលិកត្រូវបានបង្កើនឡើងជាអតិបរមានៅក្នុងបន្ទប់ ឬទីកន្លែងទាំងឡាយដែលប្រើប្រាស់ដោយបុគ្គលិកសម្រាប់ការបរិភោគអាហារ និង/ឬសម្រាក។ ចំណុចនេះសម្រេចបានដោយ៖
  - ○ បិទប្រកាសចំនួនមនុស្សអតិបរមា ដែលត្រូវគ្នានឹងការអនុញ្ញាតឲ្យមានគំលាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើប្រាស់ការសម្រាក និង
  - ○ ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក និង
  - ○ ដាក់តុឃ្លាតពីគ្នាយ៉ាងហោចណាស់ប្រាំបីហ្វីត និងធានាថាមានគំលាតប្រាំមួយហ្វីតចន្លោះកៅអី ដោយដកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋដើម្បីធានានូវការរក្សាគំលាត និងរៀបចំកន្លែងអង្គុយតាមរបៀបមួយដែលកាត់បន្ថយការប៉ះពាល់ទល់មុខគ្នាជាអប្បបរមា។ ការប្រើប្រាស់របាំងខណ្ឌចែកត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឲ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគំលាតរវាងកាយឡើយ។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ ឬផ្លាស់ប្ដូរម៉ាស់របស់ខ្លួនជារៀងរាល់ថ្ងៃ។
- ❑ ស្ថានីយការងារ ឬទីកន្លែងធ្វើការទាំងអស់ត្រូវបានបំបែកពីគ្នាយ៉ាងតិចប្រាំមួយហ្វីត។
- ❑ បន្ទប់លក់សំបុត្រ ទីកន្លែងលក់ម្ហូបអាហារ បន្ទប់សម្រាករបស់បុគ្គលិក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគតាមភាពញឹកញាប់ដូចខាងក្រោម ប៉ុន្តែមិនតិចជាងម្ដងក្នុងមួយថ្ងៃទៅតាមកាលវិភាគដូចខាងក្រោម៖
  - ○ បន្ទប់លក់សំបុត្រ ____________________________________________
  - ○ ទីកន្លែងលក់ម្ហូបអាហារ ____________________________________
  - ○ បន្ទប់សម្រាក ____________________________________________
  - ○ បន្ទប់ទឹក ____________________________________________
  - ○ ផ្សេងទៀត____________________________________________
- ❑ សារធាតុសម្លាប់មេរោគនិងការផ្គត់ផ្គង់ដែលពាក់ព័ន្ធ គឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោម៖

______________________________________________________________________________

- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

______________________________________________________________________________

- ❑ បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកឲ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។

- ❑ កម្មករនីមួយៗ ត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងលំហធ្វើការដែលបានកំណត់។ ការប្រើប្រាស់វត្ថុរួមគ្នា ដែលត្រូវប៉ះរួម ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ❑ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះ ក្រៅពីគោលការណ៍ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀត ដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។
- ❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

- ❑ ប្រព័ន្ធប្រតិបត្តិការដោយមិនប្រើសាច់ប្រាក់ និងមិនប៉ះត្រូវបានអនុវត្តនៅកន្លែងដែលអាចធ្វើបាន។ ការកក់ និងការបង់ប្រាក់អាចធ្វើឡើងជាមុនតាមអនឡាញ ឬតាមទូរស័ព្ទ។
- ❑ យានយន្តត្រូវតែឃ្លាតពីគ្នាប្រាំមួយហ្វីត និងមិនអនុញ្ញាតឲ្យមានការប្រមូលផ្តុំមនុស្សនៅខាងក្រៅយានយន្តឡើយ។ ទីធ្លាចំណតសម្រាប់ទស្សនានៅរោងភាពយន្តបើកចូលត្រូវបានដាក់កម្រិតត្រឹមកន្លែងដែលផ្លោះមួយ ឬត្រូវបានរៀបចំឡើងវិញ ដើម្បីធានាបាននូវការរក្សាគំលាតសមស្របរវាងយានយន្ត។
- ❑ យានយន្តនីមួយៗត្រូវបានដាក់កម្រិតឲ្យមានផ្ទុកតែសមាជិកនៃគ្រួសារតែមួយដែលបានប៉ះពាល់ជិតស្និទ្ធជាមួយគ្នារួចទៅហើយ។ បើសិនជាមិនប្រើប្រាស់បន្ទប់ទឹក ឬរកទិញអាហារសម្រន់ អតិថិជនត្រូវតែស្ថិតនៅក្នុងយានយន្តរបស់ខ្លួន។ អតិថិជនមិនអាចអង្គុយនៅខាងក្រៅយានយន្តរបស់ខ្លួន ដើម្បីមើលភាពយន្តបើកចូលនៅជិតយានយន្តរបស់ខ្លួនបានទេ។
- ❑ រថយន្តដែលចូលត្រូវបានហាមឃាត់មិនឲ្យលើសពីចំណុះអតិបរមារបស់ខ្លួន។
- ❑ បុគ្គលត្រូវតែស្ថិតនៅក្នុង ឬនៅលើយានយន្តរបស់ខ្លួន។ រថយន្តដែលអាចបិទបើកដំបូលបាន អាចទម្លាក់ដំបូល ហើយអ្នកមើលអាចអង្គុយលើផ្នែកខាងក្រៅនៃយានយន្តរបស់ខ្លួន ដូចជាឃ្លុបនៃរថយន្តភីកអាប់។
- ❑ បុគ្គលិកដែលពាក់ម៉ាស់ត្រូវបានដាក់ឲ្យប្រចាំការដោយឃ្លាតពីអតិថិជនផ្ទាល់ប្រាំមួយហ្វីត ដើម្បីបើកទីធ្លាចំណត។
- ❑ សួនកម្សាន្តសម្រាប់កុមារ អាចត្រូវបានបើកដំណើរការដោយអនុលោមតាមពិធីសារខោនធីសម្រាប់សួនកុមារនៅខាងក្រៅ។
- ❑ កន្លែងពិចនិក និងទីកន្លែងសម្រាប់ការកម្សាន្តរបស់មនុស្សជំមុនពេលបញ្ចាំងត្រូវបានបិទ។ អ្នកមើលមិនត្រូវប្រើកន្លែងអង្គុយខាងក្រៅអគារឡើយនិងត្រូវតែស្ថិតនៅក្នុងរថយន្ត។ កន្លែងអង្គុយខាងក្រៅអគារទាំងឡាយ ដែលស្ថិតនៅក្នុងចម្ងាយ 100 ហ្វីតពីទីកន្លែងមើល ត្រូវតែបិទមួយម៉ោងមុនម៉ោងចាក់បញ្ចាំង និងបន្តបិទរហូតដល់ផុតរយៈពេលមួយម៉ោងបន្ទាប់ពីការចាក់បញ្ចាំងចប់។
- ❑ បុគ្គលិកដែលពាក់ម៉ាស់ត្រូវបានដាក់ឲ្យប្រចាំការនៅច្រកចូលទៅកាន់កន្លែងលក់អាហារសម្រន់ និងបន្ទប់ទឹក ដោយស្ថិតនៅគំលាតប្រាំមួយហ្វីតពីគ្នា និងពីអតិថិជនដែលនៅជិតបំផុត ដើម្បីធានាបាននូវការរក្សាគំលាត 6 ហ្វីតនៅក្នុងជួរនិងនៅក្នុងទីកន្លែង។
- ❑ ប្រតិបត្តិការលក់អាហារសម្រន់ ដែលជាផ្នែកមួយនៃរោងភាពយន្តបើកចូលអចិន្ត្រៃយ៍ ត្រូវបានរៀបចំឡើងវិញ ដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយ។
    - ○ បើអាចធ្វើបាន ការបញ្ជាទិញជាមុននិងការបង់ប្រាក់តាមបែបអេឡិចត្រូនិកនៅតាមម៉ោងដែលបានកំណត់សម្រាប់ទៅយកគឺត្រូវបានផ្តល់ជូន។
    - ○ បើសិនជាអតិថិជនត្រូវបានអនុញ្ញាតឲ្យបញ្ជាទិញនិងទៅយកនៅតូបលក់អាហារសម្រន់ ពួកគេទទួលបានម៉ឺនុយ (បានបិទផ្សាយ ឬក្រដាសចែកសម្រាប់ប្រើតែម្តង) ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ការបញ្ជាទិញ ហើយការបញ្ជាទិញទំនិញ ត្រូវបានប្រមូលវេចខ្ចប់និងយកដោយអតិថិជនក្នុងរយៈពេល 15 នាទីបន្ទាប់ពីបញ្ជាទិញនៅនឹងកន្លែង។ អតិថិជនដែលរង់ចាំទំនិញ មិនអាចប្រមូលផ្តុំនៅកន្លែងលក់អាហារសម្រន់បានទេ។ ពួកគេអាចរង់ចាំ ដោយរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីគ្នា នៅឆ្ងាយពីកន្លែងលក់អាហារសម្រន់ ឬត្រឡប់ទៅរថយន្តរបស់ខ្លួនវិញ រួចមកម្តងទៀតនៅម៉ោងដែលបានកំណត់ដើម្បីទទួលយកការបញ្ជាទិញរបស់ខ្លួន។
    - ○ បើសិនជាអតិថិជនចាំបាច់ត្រូវតម្រង់ជួរដើម្បីធ្វើការបញ្ជាទិញ ឬយកម្ហូបអាហារ បង់ស្ទិកឬការសម្គាល់ផ្សេង

ទៀតបញ្ជាក់ពីកន្លែងចាប់ផ្តើមសម្រាប់អតិថិជនដែលមកដល់ដើម្បីយកទំនិញ និងគំលាត 6 ហ្វីតសម្រាប់អតិថិជនដែលមកក្រោយៗទៀតដែលចូលតម្រង់ជួរ។

- មិនអនុញ្ញាតឲ្យកុមារអាយុក្រោម 12 ឆ្នាំចូលទៅកន្លែងលក់អាហារសម្រន់ ឬបន្ទប់ទឹកតែម្នាក់ឯងឡើយ។
- មិនអនុញ្ញាតឲ្យមានមនុស្សធំច្រើនជាងពីរនាក់ក្នុងយានយន្តមួយ ដើម្បីមកយកការបញ្ជាទិញម្ហូបអាហារឡើយ។ បើសិនជាមនុស្សធំម្នាក់កំពុងមកយកការបញ្ជាទិញ ពួកគេអាចមានកុមារម្នាក់មកជាមួយ។
- តូបលក់អាហារសម្រន់ ត្រូវបានបិទសម្រាប់ការបញ្ជាទិញថ្មីៗយ៉ាងតិច 30 នាទីមុនពេលការបញ្ចាំងភាពយន្តចប់។

- ❑ បើសិនជាអតិថិជនចាំបាច់ត្រូវចូលទៅក្នុងបន្ទប់ទឹក បិតបង់ស្អិតឬការសម្គាល់ផ្សេងទៀតបញ្ជាក់ពីកន្លែងចាប់ផ្តើមសម្រាប់អតិថិជនដែលមកដល់ និងគំលាត 6 ហ្វីតសម្រាប់អតិថិជនដែលមកក្រោយៗទៀតដែលចូលតម្រង់ជួរ។
- ❑ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអតិថិជន និងពីបុគ្គលិកដូចគ្នានៅកន្លែងបញ្ជាទិញអាហារសម្រន់ កន្លែងទៅយកនិងកន្លែងបង់ប្រាក់។ បុគ្គលិកអាចមកជិតជាបណ្តោះអាសន្ននៅពេលចាំបាច់ដើម្បីទទួលយកប្រាក់ បញ្ជូនទំនិញឬផ្តល់សេវាកម្ម ឬទៅតាមការចាំបាច់។
- ❑ ការបញ្ចាំងរឿងពីរក្នុងតម្លៃមួយ (Double features)ត្រូវបានលុបបំបាត់ ហើយម៉ោងបញ្ចាំងត្រូវបានដាក់កម្រិត ឬផ្លាស់វេនដើម្បីចៀសវាងការចាំបាច់ក្នុងការសម្រាក និងទប់ស្កាត់ការកកកុញខ្លាំងនៅចន្លោះម៉ោងបញ្ចាំង។
- ❑ សន្តិសុខ និង/ឬបុគ្គលិកជាច្រើនត្រូវបានចាត់តាំងដើម្បីប្រាកដថាបុគ្គលិក និងអតិថិជនគោរពតាមសេចក្តីបង្គាប់ទាំងអស់។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ❑ ប្រព័ន្ធ HVAC នៅក្នុងបន្ទប់លក់សំបុត្របិទជិត និងកន្លែងលក់អាហារសម្រន់ និងបន្ទប់ទឹកគឺមានសភាពល្អដំណើរការធម្មតា។ ទៅតាមកម្រិតអតិបរមាដែលអាចធ្វើបាន ខ្យល់ចេញចូលត្រូវបានបង្កើន។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងៗទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងការិយាល័យ និងទីកន្លែងផ្សេងៗទៀត។
សូមមើលការណែនាំរបស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ាការណែនាំប្រព័ន្ធខ្យល់ចេញចូលតាមតម្រង និងគុណភាពខ្យល់នៅក្នុងបរិយាកាសខាងក្នុងអគារសម្រាប់ព័ត៌មានលម្អិត។
  - សូមចំណាំ៖ ប្រព័ន្ធខ្យល់ និងការកែលម្អគុណភាពខ្យល់ខាងក្នុងគឺត្រូវតែបន្ថែមទៀត និងមិនមែនជាការជំនួសការការពារដែលរួមមានការពាក់របាំងគ្របមុខ (លើកលែងតែបរិយាកាសជាក់លាក់ដែលមានហានិភ័យខ្ពស់ដែលទាមទារឲ្យមានការការពារផ្លូវដង្ហើមត្រឹមត្រូវ) រក្សាគម្លាតយ៉ាងតិច 6ហ្វីតរវាងមនុស្សនិងមនុស្ស លាងដៃឲ្យបានញឹកញាប់ និងកំណត់សកម្មភាពដែលប្រមូលផ្តុំមនុស្សមកពីគ្រួសារ ផ្សេងៗគ្នា។
- ❑ ក្រដាសសំបុត្រត្រូវបានទទួលដោយបុគ្គលិក ដែលស្ថិតនៅក្នុងបន្ទប់មួយ ដោយពាក់ម៉ាស់ និងការពារដោយរបាំងសមស្រប។ សំបុត្រ ឬបង្កាន់ដៃអេឡិចត្រូនិក អាចត្រូវបានស្កេនដោយបុគ្គលិកនៅក្នុងបន្ទប់ដែលបានការពារខាងលើ ឬដោយបុគ្គលិកស្ថិតនៅទីវាលដែលពាក់ម៉ាស់។
- ❑ វត្ថុនិងផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់នៅក្នុងបន្ទប់ទឹក ក៏ដូចជាកន្លែងយកអាហារសម្រន់ និងកន្លែងបង់ប្រាក់ (ឧ. បញ្ជរ ដៃទ្វារឬដៃកាន់ ម៉ាស៊ីនអានកាតឥណទាន) ត្រូវបានសម្លាប់មេរោគយ៉ាងហោចណាស់មួយថ្ងៃម្តងក្នុងអំឡុងម៉ោងធ្វើការ ដោយប្រើសារធាតុសម្លាប់មេរោគដែលបានអនុញ្ញាតដោយ EPA។
- ❑ ទីកន្លែងការងារ និងអគារទាំងមូលត្រូវបានសម្អាតយ៉ាងតិចជាប្រចាំថ្ងៃ ដោយបន្ទប់ទឹកនិងតំបន់/វត្ថុដែលបានប៉ះញឹកញាប់ ត្រូវបានសម្អាតញឹកញាប់ ប្រសិនបើបានកំណត់ចាំបាច់។
- ❑ អតិថិជនដែលមកដល់អាជីវកម្មត្រូវបានរំលឹកឲ្យពាក់ម៉ាស់គ្រប់ពេលវេលា (លើកលែងពេលបរិភោគ ឬផឹកបើសិនជាអាចធ្វើបាន) ខណៈពេលនៅក្នុងអាជីវកម្ម ឬលើទីធ្លារបស់អាជីវកម្ម។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ បុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់ម៉ាស់ដោយអ្នកផ្តល់សេវា វេជ្ជសាស្ត្ររបស់ខ្លួនត្រូវតែពាក់របាំងមុខដែលមានក្រណាត់បិទជិតនឹងគែមខាងក្រោម

ដោយគោរពតាមសេចក្តីណែនាំរបស់រដ្ឋ លុះត្រាណាតែលក្ខខណ្ឌរបស់ពួកទទួលបានការអនុញ្ញាតនេះ។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិកអ្នកនិងភ្ញៀវផ្សេងទៀត គេគួរផ្តល់របាំងមុខដល់ភ្ញៀវដែលមកដល់ដោយមិនមានម៉ាស។

- ❑ ការពិនិត្យច្រកចូល ត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចចូលក្នុងទីតាំងអាជីវកម្មទាំងខាងក្នុង ឬខាងក្រៅអគារ។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម គ្រុនក្ដៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្ដីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬទេ (សូមមើលការណែនាំខោនធី ការត្រួតពិនិត្យច្រកចូល)។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាប្រព័ន្ធចុះឈ្មោះតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថា ភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
  - o ការត្រួតពិនិត្យទទួលលទ្ធផលអវិជ្ជមាន (ស្អាត)។ ប្រសិនបើបុគ្គលនោះមិនមានរោគសញ្ញា និងគ្មានទំនាក់ទំនងជាមួយករណីជំងឺ COVID-19 ដែលបានរកឃើញក្នុងរយៈពេល 10 ថ្ងៃចុងក្រោយនេះទេ ពួកគេគឺស្អាត ហើយអាចចូលទៅទីតាំងបានសម្រាប់ថ្ងៃនោះ។
  - o ការត្រួតពិនិត្យទទួលលទ្ធផលវិជ្ជមាន (មិនស្អាត)៖
    - ▪ ប្រសិនបើបុគ្គលនោះបានទាក់ទងជាមួយករណីជំងឺ COVID-19 ដែលបានរកឃើញក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬថ្មីៗនេះស្ថិតនៅក្រោមការដាក់ឲ្យនៅដាច់ដោយឡែក ពួកគេមិនអាចចូលទីតាំងនេះបានទេ ហើយត្រូវបញ្ជូនទៅផ្ទះភ្លាមៗដើម្បីដាក់ឲ្យនៅដាច់ដោយឡែកនៅក្នុងផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការធ្វើចត្តាឡីស័ក (នៅដាច់ដោយឡែក) ដល់ពួកគេដែលមាននៅលើគេហទំព័រ ph.lacounty.gov/covidquarantine។
    - ▪ ប្រសិនបើមនុស្សនោះបង្ហាញរោគសញ្ញាដែលត្រូវបានកំណត់សម្គាល់ដូចខាងលើ ឬកំពុងស្ថិតនៅក្រោមការបញ្ជាឲ្យធ្វើចត្តាឡីស័ក (ការដាក់ឲ្យនៅដាច់ដោយឡែក) គេមិនអាចចូលបានទេ ហើយត្រូវតែបញ្ជូនទៅផ្ទះវិញភ្លាមៗដើម្បីធ្វើចត្តាឡីស័កនៅផ្ទះ។ ដោយត្រូវផ្តល់ការណែនាំនៃការនៅដាច់ដោយឡែកដល់ពួកគេដែលមាននៅលើគេហទំព័រ ph.lacounty.gov/covidisolation។
- ❑ អតិថិជនដែលមកដល់ទីកន្លែងជាមួយកុមារ ត្រូវតែប្រាកដថា កុមារមិនចាកចេញពីរថយន្តរបស់ខ្លួនតែម្នាក់ឯងឡើយ។ បើសិនជាកុមារចាំបាច់ត្រូវតែទៅបន្ទប់ទឹក ឬទៅជាមួយមនុស្សធំនៅកន្លែងលក់អាហារសម្រន់ មនុស្សធំដែលទៅជាមួយត្រូវតែប្រាកដថា កុមារស្ថិតនៅជិតខ្លួន មិនប៉ះអ្នកដទៃ ឬវត្ថុណាមួយដែលមិនមែនជារបស់ពួកគេ និងពាក់ម៉ាស់បើសិនជាគ្រប់អាយុ។
- ❑ ទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាមគឺមានសម្រាប់ភ្ញៀវនៅ ឬជិតច្រកចូលបន្ទប់ទឹក និងទីកន្លែងលក់អាហារសម្រន់។
- ❑ ស្រេចចិត្ត - ពិពណ៌នាពីវិធានការណ៍គ្រប់គ្រងការឆ្លងជំងឺផ្សេងទៀត៖

______________________________________________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណៈជន

- ❑ ច្បាប់ចម្លងនៃពិធីសារនេះ ឬបើអាចពាក់ព័ន្ធគ្នា ឬវិញ្ញាបនបត្រអនុលោមតាមសុវត្ថិភាពនៃជំងឺCOVID-19 របស់ខោនធី Los Angeles ត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងអគារ។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញតាមកម្មវិធីបញ្ជាក់វិញ្ញាបនបត្រដោយខ្លួនឯង ដោយអនុលោមតាមសុវត្ថិភាពជំងឺ COVID-19 សូមចូលទៅកាន់គេហទំព័រ http://publichealth.lacounty.gov/eh/20covid19/safety-compliance-certificate-program.htm។ អាជីវកម្មទាំងអស់ត្រូវតែរក្សាទុកច្បាប់ចម្លងនៃពិធីសារនៅទីតាំងការងារដើម្បីកែសម្រួល តាមការស្នើសុំ។
- ❑ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្ដាញសង្គម ។ល។) ណែនាំដល់អតិថិជន ពីរបៀបទិញសំបុត្រតាមអនឡាញនិងគោលការណ៍ផ្សេងៗ ដែលទាក់ទងនឹងភស្តុតាងនៃការទិញនៅទីកន្លែង។
- ❑ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្ដាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងបើកដំណើរការ

ការតម្រូវឲ្យប្រើម៉ាស់ គោលការណ៍ទាក់ទងនឹងការបញ្ជាទិញជាមុន ការបង់ប្រាក់ជាមុន ការមកយក និង/ឬការដឹកជញ្ជូនអាហារសម្រន់និងបញ្ហាផ្សេងៗទៀត។ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូល សាធារណៈទាំងអស់មកក្នុងអគារ។

- ❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយដើម្បីផ្តល់ការណែនាំច្បាស់លាស់ដល់សាធារណជនអំពីរបៀបរក្សាសុវត្ថិភាពនៅក្នុងទីតាំងអាជីវកម្មនោះ (ឧទាហរណ៍ ការរក្សាគម្លាតឃ្លាតរាងកាយ ពាក់ម៉ាស់។ល។) ។ សូមមើលការណែនាំនៃជំងឺ COVID-19 របស់ខោនធី DPH៖ http://publichealth.lacounty.gov/media/Coronavirus/guidances.htm#business សម្រាប់ឯកសារបន្ថែម និងឧទាហរណ៍នៃផ្លាកសញ្ញាដែលអាចយកទៅប្រើតាមអាជីវកម្មផ្សេងៗ។
- ❑ ស្លាកសញ្ញាដែលអាចមើលឃើញនៅច្រកចូលក្នុងទីកន្លែង និងទីកន្លែងនានាដែលអតិថិជនតម្រង់ជួរ ជូនដំណឹងដល់អតិថិជន អំពីសេចក្តីបង្គាប់ទាក់ទងនឹងការរក្សាគំលាតរាងកាយ និងការគ្រប់គ្រងការឆ្លងជំងឺ ដែលរួមមាន៖
  - o ការហាមឃាត់ការប្រមូលផ្តុំ ឬការមើលនៅខាងក្រៅរថយន្ត
  - o លទ្ធភាពក្នុងការបញ្ជាទិញជាមុនពីតូបលក់អាហារសម្រន់
  - o តម្រូវឲ្យប្រើក្រណាត់បាំងមុខ នៅពេលទៅតូបលក់អាហារសម្រន់ ឬបន្ទប់ទឹក
  - o តម្រូវឲ្យមនុស្សធំត្រួតពិនិត្យកុមារតូចៗ
  - o ការអនុវត្តតាមការណែនាំរបស់បុគ្គលិក ដោយក្តីគោរពទាក់ទងនឹងបទប្បញ្ញត្តិខាងលើ។
- ❑ សេចក្តីប្រកាសលើអេក្រង់មុនពេលចាក់បញ្ចាំង ត្រូវបានប្រើដើម្បីពង្រឹងការយល់ដឹងរបស់អតិថិជន អំពីសេចក្តីបង្គាប់ទាក់ទងនឹងការរក្សាគំលាតរាងកាយ និងការគ្រប់គ្រងការឆ្លងជំងឺ ដូចខាងលើ។
- ❑ ម៉ឺនុយទំនិញដែលមានសម្រាប់ទិញ គឺមានរួចរាល់សម្រាប់អតិថិជនដែលមានគម្រោងទិញនៅនឹងកន្លែងនៅតូបលក់អាហារសម្រន់។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់ភ្ញៀវ/អតិថិជនត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយ ត្រូវបានប្តូរទៅជាអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្ត ដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជនដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។

## F. ការរៀបចំបណ្តោះអាសន្ន ឬព្រឹត្តិការណ៍ពិសេសនៅក្នុងចំណតយានយន្ត ឬទីកន្លែងផ្សេងទៀត

- ❑ **ការជូនដំណឹងសុខភាពសាធារណៈ។** ស្ថាប័នដែលចង់បង្កើតប្រតិបត្តិការបញ្ចាំងភាពយន្តដោយបើកចូល ឬការសម្តែងផ្ទាល់ដោយបើកចូលនៅលើទីតាំងដែលជាធម្មតាមិនត្រូវបានប្រើសម្រាប់គោលបំណងនោះ គួរដាក់ស្នើផែនការជាលាយលក្ខណ៍អក្សរ ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាព និងសុខភាពទាំងអស់ទៅកាន់ ehmail@ph.lacounty.gov ជាមុនយ៉ាងតិចបំផុត 7 ថ្ងៃ។ ផ្នែកសុខភាពបរិស្ថាន (Environmental Health) ក៏អាចតម្រូវឲ្យមានការធ្វើអធិការកិច្ចត្រួតពិនិត្យដើម្បីវាយតម្លៃទីតាំង និងទីកន្លែងផងដែរ។
- ❑ **ទំហំទីតាំង។** ទីតាំងត្រូវតែធំល្មមដើម្បីផ្ទុកចំនួនភ្ញៀវដែលបានរំពឹងទុក និងយានយន្តរបស់ពួកគេដោយរក្សាគំលាត 6 ហ្វីត ឬច្រើនជាងនេះរវាងរថយន្តទាំងអស់ មានទីធ្លាគ្រប់គ្រាន់សម្រាប់បន្ទប់ទឹក កន្លែងលាងដៃ កន្លែងបញ្ចាំងភាពយន្ត និងកន្លែងបុគ្គលិកសម្រាក។
- ❑ **ការគ្រប់គ្រងបរិវេណ និងអ្នកចូលរួម។** បង្កើតផែនការមួយដែលកំណត់ពីចំនួនផ្ទុកអតិបរមា ដើម្បីគោរពតាមការរឹតបន្តឹងសុខភាពសាធារណៈដោយធានាបាននូវច្រកចេញចូលដែលមានការគ្រប់គ្រង។
- ❑ **ម្ហូបអាហារ។** សេវាកម្មម្ហូបអាហារទាំងឡាយ ត្រូវតែមកពីភោជនីយដ្ឋាននៅនឹងកន្លែង ឬទីផ្សារដែលបានអនុញ្ញាតដោយផ្នែកសុខភាពបរិស្ថាន។ ម្ហូបអាហារអាចទិញបាននិងមកយកនៅនឹងកន្លែង ឬបញ្ជាទិញតាមរយៈសេវាកម្មដឹកជញ្ជូនភាគីទីបី និងដឹកជញ្ជូនទៅកាន់យានយន្តរបស់អតិថិជន។ ទីកន្លែងលក់ម្ហូបអាហារទាំងនេះ ត្រូវតែគោរពតាមពិធីការបើកឡើងវិញជាធរមានទាំងអស់។ អ្នកចូលរួមអាចយកម្ហូបអាហាររបស់ខ្លួនមកជាមួយបាន។ តូបលក់អាហារសម្រន់បណ្តោះអាសន្ន កន្លែងលក់អាហារសម្រន់ដែលមិនបានអនុញ្ញាត ឬទីកន្លែងលក់ម្ហូបអាហារ

ផ្សេងៗទៀត (ឧ. ការចែកជូនម្ហូបអាហារ ឡានលក់អាហារ និងរទេះរុញលក់អាហារ) គឺមិនត្រូវបានអនុញ្ញាតឡើយ។

- ❑ **បន្ទប់ទឹក និងការលាងដៃ។** បើសិនជាបន្ទប់ទឹកនិងកន្លែងលាងដៃមិនអាចប្រើបាន ឬមានមិនគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការរបស់អ្នកចូលរួមដែលបានរំពឹងទុក ត្រូវតែផ្តល់បន្ទប់ទឹកនិងកន្លែងលាងដៃចល័ត។ ត្រូវតែមានបង្គន់ 1 និងកន្លែងលាងដៃ 2 ក្នុងអ្នកចូលរួម 100 នាក់។

## G. ការប្រគុំតន្ត្រី និងការសម្តែងផ្ទាល់

- ❑ បុគ្គលិក ក្រុមការងារ តន្ត្រីករនិងអ្នកសម្តែងទាំងអស់ ត្រូវបានណែនាំឲ្យពាក់របាំងមុខ និងរក្សាគំលាតយ៉ាងតិចប្រាំមួយ (6) ហ្វិតពីគ្នានៅគ្រប់ពេលវេលា លើកលែងនៅពេលកិច្ចការជាក់លាក់តម្រូវឲ្យធ្វើការជិតគ្នាជាងនេះ។
- ❑ កិច្ចសន្យា នាដកថា ក្រដាសណោតតន្ត្រី និងឯកសារផ្សេងៗទៀតទាំងអស់ដែលជាធម្មតាត្រូវបានចែករំលែក គឺត្រូវចែករំលែកតាមបែបឌីជីថល ឬត្រូវបានបោះពុម្ព និងចែកជូនម្នាក់ៗទៅក្រុមការងារ តន្ត្រីករ និងអ្នកសម្តែង ដើម្បីចៀសវាងការចែករំលែក។
- ❑ នៅគ្រប់ពេលដែលអាចធ្វើបាន មនុស្សគ្រប់គ្នាគួរប្រើឧបករណ៍របស់ខ្លួន (រួមមានកាសស្តាប់ត្រចៀក មីក្រូហ្វូន ខន់សូល) គ្រឿងផ្គត់ផ្គង់។ល។ បើសិនជាចាំបាច់ត្រូវតែចែករំលែកឧបករណ៍ គួរធ្វើអនាម័យវាបន្ទាប់ពីប្រើប្រាស់ម្តងៗ។
- ❑ ត្រូវតែផ្តល់គ្រឿងសម្គាល់គំលាត ដើម្បីចង្អុលបង្ហាញពីការរក្សាគំលាតសង្គមគ្រប់គ្រាន់។ មីក្រូហ្វូន ខន់សូល និងឧបករណ៍ផ្សេងៗទៀត ត្រូវតែរៀបចំឡើងដើម្បីសម្រួលដល់ការរក្សាគំលាតសង្គម។
- ❑ តន្ត្រីករ និងអ្នកចម្រៀងទាំងអស់ដែលធ្វើការសម្តែងដោយមិនអាចពាក់របាំងមុខបាន (ឧ. អ្នកលេងឧបករណ៍ផ្លុំ ឬត្រែ អ្នកចម្រៀង) គួររក្សាគំលាតសង្គមយ៉ាងតិច 12 ហ្វិតក្នុងអំឡុងការហាត់សមនិងការសម្តែង។ ម្យ៉ាងវិញទៀត បុគ្គលទាំងនេះ គួរស្ថិតនៅដាច់ដោយឡែកពីអ្នកដទៃ និងពីគ្នាដោយកញ្ចក់ Plexiglass ឬរបាំងផ្សេងៗទៀត។
- ❑ តារាងទាំងនេះត្រូវតែមកដល់ដោយបានធ្វើសក់ និងផាត់មុខរួចស្រេចហើយ។
- ❑ ការសម្តែងផ្ទាល់នៅខាងក្រៅអគារទាំងអស់ត្រូវតែគោរពតាមពិធីការព្រឹត្តិការណ៍បន្តផ្ទាល់នៅខាងក្រៅអគារ ឧបសម្ព័ន្ធ Z។

**វិធានការណ៍បន្ថែមណាមួយដែលមិនបានរៀបរាប់ខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម៖** ______________ **លេខទូរស័ព្ទ៖** ______________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ______________

ត្រូវបានលុបចោល - មិនមានប្រសិទ្ធភាពទៀតទេ